# សលាកបត្រព័ត៌មាន: អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម

**ទិដ្ឋភាពរួម:** អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម("អ្នករាយការណ៍ពិសេស")គឺជាយន្តការនៃអង្គការសហប្រជាជាតិ មានអាណត្តិក្នុងការរាយការណ៍ និងផ្តល់អនុសាសន៍អំពីសេរីភាពជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគមនៅជុំវិញពិភពលោក ក្នុងគោលបំណងធ្វើឱ្យប្រសើរដល់ការគោរពសិទ្ធិមនុស្ស។ សលាកបត្រព័ត៌មាននេះ បង្ហាញអំពីបញ្ហាសំខាន់ៗនិងរបកគំហើញដែលអ្នករាយការណ៍ពិសេសបានលើកឡើងក្នុងរបាយការណ៍តាមវិស័យជាក់លាក់មួយចំនួន ក្នុងនោះរួមទាំងអំពីទំនាក់ទំនងរវាងការអនុវត្តសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគម លំហសេរីភាពនៃពលរដ្ឋ ការអភិវឌ្ឍប្រកបដោយចីរភាព និងការអនុវត្តសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅលើប្រព័ន្ធបច្ចេកវិទ្យា។ សលាកបត្រព័ត៌មាននេះក៏គូសបញ្ជាក់ផងដែរអំពីស្ថានភាពនៃសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមនៅព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា") និងឆ្លុះបញ្ចាំងទៅនឹងរបកគំហើញរបស់អ្នករាយការណ៍ពិសេស ព្រមទាំងផ្តល់អនុសាសន៍ផងដែរ។

## ១. សេចក្តីផ្តើម

សិទ្ធិសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម គឺជាសសរស្តម្ភនៃសិទ្ធិមនុស្សអន្តរជាតិ។ អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម ("អ្នករាយការណ៍ពិសេស") មានអាណត្តិត្រូវបំពេញតួនាទីផ្សេងៗក្នុងគោលបំណងលើកកម្ពស់និងការពារសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅទូទាំងពិភពលោក[1]។ សលាកប័ត្រព័ត៌មាននេះនឹងគូសបញ្ជាក់អំពីសិទ្ធិមូលដ្ឋាននៃសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម បង្ហាញអំពីទំនាក់ទំនងសំខាន់រវាងការអនុវត្តសេរីភាពក្នុងការជួបប្រជុំនិងការចងក្រងសមាគម លំហសេរីភាពរបស់ពលរដ្ឋ និងការអភិវឌ្ឍប្រកបដោយចីរភាព ហើយនិងការអនុវត្តសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមនៅលើប្រព័ន្ធបច្ចេកវិទ្យា តាមការលើកឡើងរបស់អ្នករាយការណ៍ពិសេសក្នុងរបាយការណ៍តាមវិស័យជាក់លាក់មួយចំនួន។ម្យ៉ាងទៀត សលាកបត្រព័ត៌មាននេះលើកឡើងនូវស្ថានភាពនៃសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគមនៅកម្ពុជា ក្នុងរយៈពេលប៉ុន្មានឆ្នាំកន្លងមកនេះ និងនៅក្នុងអំឡុងពេលរាតត្បាតនៃជំងឺកូវីដ-១៩។

---

[1] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "អាណត្តិការងាររបស់អ្នករាយការណ៍ពិសេស" https://www.ohchr.org/EN/Issues/AssemblyAssociation/Pages/Mandate.aspx។

សលាកបត្រព័ត៌មាននេះចងក្រងដោយមជ្ឈមណ្ឌលសិទ្ធិមនុស្សកម្ពុជា ("ម.ស.ម.ក")។ ម.ស.ម.ក គឺជាអង្គការមិនមែនរដ្ឋាភិបាល ឯករាជ្យ មិនចូលបក្ខសម្ព័ន្ធ ដែលធ្វើការងារដើម្បីលើកកម្ពស់ និងការពារលទ្ធិប្រជាធិបតេយ្យ និងការគោរពសិទ្ធិមនុស្សនៅទូទាំងព្រះរាជាណាចក្រកម្ពុជា ("កម្ពុជា")។

## ២. របកគំហើញក្នុងរបាយការណ៍អ្នករាយការណ៍ពិសេស

*តើអ្នករាយការណ៍ពិសេសជានរណា?*

អ្នករាយការណ៍ពិសេសអង្គការសហប្រជាជាតិ គឺជាអ្នកជំនាញឯករាជ្យដែលមានអាណត្តិក្នុងការរាយការណ៍និងផ្តល់អនុសាសន៍អំពីស្ថានភាពសិទ្ធិមនុស្សក្នុងប្រទេសណាមួយឬក៏ប្រធានបទទាក់ទងនឹងសិទ្ធិមនុស្សជាក់លាក់ណាមួយ។ អ្នករាយការណ៍ពិសេស ត្រូវបានបង្កើតឡើងក្នុងឆ្នាំ២០១០តាមរយៈសេចក្តីសម្រេចនៃក្រុមប្រឹក្សាសិទ្ធិមនុស្សលេខ១៥/២១ និងមានអាណត្តិត្រូវបំពេញតួនាទីផ្សេងៗដើម្បីលើកកម្ពស់ និងការពារសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម[2]។

*តើសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគមគឺជាអ្វី?*

អ្នករាយការណ៍ពិសេស ផ្តល់និយមន័យសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី ថាគឺជាសិទ្ធិបញ្ចេញគំនិតយោបល់ជាសមូហភាពតាមរយៈការរៀបចំបាតុកម្ម ឬការប្រមូលផ្តុំជាសាធារណៈដើម្បីទាញការចាប់អារម្មណ៍ពីសំណាក់រដ្ឋាភិបាល បណ្តាញផ្សព្វផ្សាយ និងសាធារណជន។ សិទ្ធិនេះរាប់បញ្ចូលទាំងសិទ្ធិចូលរួមក្នុងការប្រមូលផ្តុំ ការជួបប្រជុំ ការតវ៉ា កូដកម្ម ការប្រមូលផ្តុំគ្នាទាមទារនៅតាមស្ថាប័នសាធារណៈ ការធ្វើបាតុកម្ម និងការប្រមូលផ្តុំក្នុងគោលបំណងជាក់លាក់ណាមួយ។ អ្នករាយការណ៍ពិសេស ផ្តល់និយមន័យសេរីភាពក្នុងការចងក្រងសមាគមថាគឺជាក្រុមនៃរូបវន្តបុគ្គល ឬនីតិបុគ្គលណាមួយដែលសហការគ្នាធ្វើសកម្មភាពជាសមូហភាព ដូចជា ការសម្តែងមតិ ការផ្សព្វផ្សាយ ការទាមទារឬការពារនូវផលប្រយោជន៍រួមនៃវិស័យណាមួយ។ សមាគម អាចជាអង្គការមិនមែនរដ្ឋាភិបាល អង្គការសង្គមស៊ីវិល ក្លឹប សមាគមខាងសាសនា គណបក្សនយោបាយ សហជីព មូលនិធិ និងសមាគមលើប្រព័ន្ធអ៊ីនធឺណិតជាដើម។ សិទ្ធិនេះការពារដូចគ្នាចំពោះសមាគមដែលបានចុះបញ្ជី និងពុំបានចុះបញ្ជី។

[2] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេស" ចេញផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ អ.ស.ប ក/ក្រុមប្រឹក្សាសិទ្ធិមនុស្ស/២០/២៧ ទំព័រ៧ កថាខ័ណ្ឌ១៣ https://undocs.org/A/HRC/20/27។

## ទំនាក់ទំនងរវាងសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម លំហសេរីភាពនៃពលរដ្ឋ និងការអភិវឌ្ឍប្រកបដោយចីរភាព

- អ្នករាយការណ៍ពិសេសបានរកឃើញថា ការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម មានសារៈសំខាន់ដល់ការអភិវឌ្ឍប្រកបដោយចីរភាពនិងការសម្រេចបាននូវរបៀបវារៈនៃគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពឆ្នាំ២០៣០។[5] នេះគឺដោយសារសិទ្ធិទាំងនេះបង្កភាពងាយស្រួលអោយប្រជាពលរដ្ឋធ្វើទំនាក់ទំនង ចល័ត និងចូលរួម ព្រមទាំងធានាថាប្រជាពលរដ្ឋមានសំឡេងនិងអាចចូលរួមចំណែកក្នុងការបង្កើតផលប្រយោជន៍រួម។[6]
- អ្នករាយការណ៍ពិសេសបានកំណត់យកចំណុចសំខាន់ៗចំនួនប្រាំ ដែលសិទ្ធិសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមមានសារៈសំខាន់ដល់ការអភិវឌ្ឍប្រកបដោយចីរភាព គឺទី១–ការធានាដល់**ការចូលរួម** និង **បរិយាប័ន្ន** ទី២–បង្កើត**ឱកាសងាយស្រួល**សម្រាប់**សង្គមស៊ីវិល** ទី៣–ធានា**តម្លាភាព** និង**គណនេយ្យភាព** ទី៤–បង្កើតភាពជាដៃគូ និង ទី៥– គាំទ្រសិទ្ធិការងារ។[7]
- អ្នករាយការណ៍ពិសេសបានសម្តែងក្តីបារម្ភថា លំហសេរីភាពរបស់ពលរដ្ឋកំពុងត្រូវបានបំបិទនៅទូទាំងពិភពលោក ខណៈដែលរដ្ឋនានាបង្កើនការរឹតត្បិតសង្គមស៊ីវិលនិងរារាំងបុគ្គលនានា និងសង្គមស៊ីវិលពីការអនុវត្តសិទ្ធិរបស់ពួកគេដោយសេរី។ យោងតាមអ្នករាយការណ៍ពិសេស អង្គការ

### តើរបៀបវារៈឆ្នាំ២០៣០ សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព (របៀបវារៈ ឆ្នាំ២០៣០) ជាអ្វី?

របៀបវារៈឆ្នាំ២០៣០ បញ្ចូលគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពចំនួន១៧ ដែលនេះជាការអំពាវនាវឱ្យមានវិធានការជាក់លាក់ដើម្បីបញ្ចប់ភាពក្រីក្រ ការការពារភពផែនដីនិងការធ្វើឱ្យប្រសើរដល់ជីវភាពរស់នៅរបស់មនុស្សនៅជុំវិញពិភពលោក។ រាជរដ្ឋាភិបាលកម្ពុជាបានគាំទ្រគោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាពនៅក្នុងឆ្នាំ២០១៥ និងបានធ្វើមូលដ្ឋានីយកម្មគោលដៅទាំងនោះមកក្នុងបរិការណ៍កម្ពុជា។[3] គោលដៅទី១៦ បញ្ចូលការការពារសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគមនៅក្នុងចំណុចដៅមួយចំនួនរបស់ខ្លួន។[4]

**គោលដៅទី ១៦**

លើកកម្ពស់សង្គមដែលមានសន្តិភាពនិងប្រកបដោយបរិយាប័ន្នដើម្បីការអភិវឌ្ឍប្រកបដោយចីរភាព ផ្តល់នូវការទទួលបានយុត្តិធម៌សម្រាប់ប្រជាជនគ្រប់រូបនឹងកសាងស្ថាប័នដែលមានប្រសិទ្ធភាព គណនេយ្យភាព និងបរិយាប័ន្ននៅគ្រប់កម្រិត។

---

[3] ព្រះរាជាណាចក្រកម្ពុជា " ការត្រួតពិនិត្យថ្នាក់ជាតិដោយស្ម័គ្រចិត្តរបស់កម្ពុជាឆ្នាំ២០១៩ ស្តីពីការអនុវត្តរបៀបវារៈឆ្នាំ២០៣០សម្រាប់ការអភិវឌ្ឍប្រកបដោយចីរភាព" (ខែមិថុនា ឆ្នាំ២០១៩)។ https://sustainabledevelopment.un.org/content/documents/23603Cambodia_VNR_SDPM_Approved.pdf។

[4] អង្គការសហប្រជាជាតិៈ "គោលដៅអភិវឌ្ឍន៍ប្រកបដោយចីរភាព" គោលដៅ១៦ https://www.un.org/sustainabledevelopment/peace-justice/។

[5] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេស" ចេញផ្សាយនៅថ្ងៃទី៧ ខែសីហា ឆ្នាំ២០១៨ អ.ស.ប ក/៧៤/៣៤៩ ទំព័រ៣ https://undocs.org/A/73/279។

[6] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេស" ចេញផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ អ.ស.ប ក/៧៤/៣៤៩ ទំព័រ១៩ https://undocs.org/A/73/279។

[7] ប្រភពខាងលើ ទំព័រ ៤-១៣។

សង្គមស៊ីវិលដែលសកម្ម និងពុំរងការរឹតត្បិតគឺមានសារៈសំខាន់ដល់ការចូលរួមក្នុងការអភិវឌ្ឍនិងការកាត់បន្ថយភាពក្រីក្រ ការចូលរួមនយោបាយ អភិបាលកិច្ចល្អ សេដ្ឋកិច្ច និងការងារផ្សេងៗទៀត។[8]

## និន្នាការសកលនៃការរឹតត្បិតសេរីភាពជួបប្រជុំ និងចងក្រងសមាគម

អ្នករាយការណ៍ពិសេសបានកំណត់នូវ**និន្នាការសកលចំនួន៨** ដែលរដ្ឋនានាធ្វើការរឹតត្បិតទៅលើលទ្ធភាពនៃការអនុវត្តសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម ដូចជា:

១. ការប្រើប្រាស់ច្បាប់ដើម្បីរឹតត្បិតទៅលើការអនុវត្តសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគម។
២. ការប្រើកម្លាំងលើសលប់ដើម្បីតបតទៅនឹងការតវ៉ាដោយសន្តិវិធី។
៣. ការប្រើកម្លាំងបង្ក្រាបទៅលើចលនាសង្គម។
៤. ការគិតបែបអគតិនិងការវាយប្រហារទៅលើតួអង្គសង្គមស៊ីវិល។
៥. ការរឹតត្បិតតាមរយៈការកំណត់មុខសញ្ញាលើក្រុមជាក់លាក់។
៦. ការដាក់កម្រិតទៅលើសិទ្ធិនានាក្នុងអំឡុងពេលបោះឆ្នោត។
៧. ផលប៉ះពាល់អវិជ្ជមាននៃការប្រកាន់គំនិតប្រជាប្រិយភាពនិយម និងភាពជ្រុលនិយម។
៨. ការរាំងស្ទះនានាដែលកើតឡើងនៅក្នុងលំហប្រព័ន្ធបច្ចេកវិទ្យា។

## សិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅយុគសម័យបច្ចេកវិទ្យា

**អ្នករាយការណ៍ពិសេសបានកំណត់បញ្ហាប្រឈមចំពោះសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម រួមមាន:**

- ច្បាប់មួយចំនួនកំណត់មាតិកា និងសកម្មភាពលើប្រព័ន្ធអ៊ីនធឺណិតជាបទល្មើសព្រហ្មទណ្ឌ (ឧទាហរណ៍ ច្បាប់ប្រឆាំងនឹងបទល្មើសតាមប្រព័ន្ធបច្ចេកវិទ្យា ច្បាប់ស្តីពីការប្រឆាំងនឹងភេរវកម្ម បញ្ញត្តិទាក់ទងនឹងការត្រួតពិនិត្យ និងច្បាប់ប្រឆាំងនឹងដំណឹងក្លែងក្លាយ)
- ផ្តាច់បណ្តាញទំនាក់ទំនងក្នុងអំឡុងពេលបោះឆ្នោត និងការធ្វើបាតុកម្មនានា
- រាំងខ្ទប់គេហទំព័រ និង
- ការត្រួតពិនិត្យលើប្រព័ន្ធបច្ចេកវិទ្យា និងការឃាំឃើសង្គមស៊ីវិល និងសំឡេងជំទាស់។

អ្នករាយការណ៍ពិសេសបានលើកឡើងបន្ថែមលើការផ្តល់ឱកាសថ្មីសម្រាប់អនុវត្តសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមថាយុគសម័យបច្ចេកវិទ្យាក៏បានបង្កើតការគំរាមកំហែងថ្មីចំពោះការអនុវត្ត សិទ្ធិទាំងនេះផងដែរ។[9] អ្នករាយការណ៍បានគូសបញ្ជាក់ថាគោលការណ៍ច្បាប់សិទ្ធិមនុស្សអន្តរជាតិក្នុងការការពារសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមត្រូវបានយកមកអនុវត្តសម្រាប់ការអនុវត្តសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមនៅលើប្រព័ន្ធបច្ចេកវិទ្យា និងបានលើកឡើងថា រដ្ឋនិងក្រុមហ៊ុនបច្ចេកវិទ្យាត្រូវការពារសិទ្ធិបច្ចេកវិទ្យា[10] ដោយណែនាំអោយក្រុមហ៊ុនទាំងនោះអនុវត្តតាមគោលការណ៍សិទ្ធិមនុស្ស។

---

[8] ប្រភពខាងលើទំព័រ ៩-១២។
[9] ការិយាល័យនៃឧត្តមស្នងការទទួលបន្ទុកសិទ្ធិមនុស្សនៃអង្គការសហប្រជាជាតិ "របាយការណ៍របស់អ្នករាយការណ៍ពិសេស" ចេញផ្សាយនៅថ្ងៃទី១១ ខែកញ្ញា ឆ្នាំ២០១៩ អ.ស.ប ក/ក្រុមប្រឹក្សាសិទ្ធិមនុស្ស/៤១/៤១/ទំព័រ២ និងទំព័រ៨-១៥ https://undocs.org/A/HRC/41/41។
[10] ប្រភពខាងលើទំព័រ៤-៥។

*ក្របខ័ណ្ឌច្បាប់ការពារសេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគម*

- **ច្បាប់អន្តរជាតិ៖** សេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមមានចែងក្នុងមាត្រា២០ នៃសេចក្តីប្រកាសជាសកលស្តីពីសិទ្ធិមនុស្ស មាត្រា២១ និងមាត្រា ២២ នៃកតិកាសញ្ញាអន្តរជាតិស្តីពីសិទ្ធិពលរដ្ឋនិងសិទ្ធិនយោបាយ ("ក.អ.ស.ព.ន")។ ក្រោមច្បាប់អន្តរជាតិ សិទ្ធិទាំងនេះត្រូវបានធានាចំពោះមនុស្សគ្រប់រូបដោយពុំមានការបែងចែក ហើយការរឹតត្បិតត្រូវតែអនុលោមជាមួយលក្ខខណ្ឌផ្នែកច្បាប់ដែលតឹងរ៉ឹង។[11]
- **ច្បាប់ជាតិ៖** មាត្រា៣១ នៃរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា ("រដ្ឋធម្មនុញ្ញ") ផ្តល់ធម្មនុញ្ញភាពលើសន្ធិសញ្ញាអន្តរជាតិនានាដែលប្រទេសកម្ពុជាបានផ្តល់សច្ចាប័នរួចហើយ ក្នុងនោះរួមទាំង ក.អ.ស.ព.ន ដែលបង្កើតបានជាកាតព្វកិច្ចត្រូវអនុវត្តដោយផ្ទាល់ក្នុងច្បាប់ជាតិ។[12] រដ្ឋធម្មនុញ្ញព្រមទាំងបានការពារសិទ្ធិទាំងនេះដោយផ្ទាល់ផងដែរក្រោមមាត្រា៤២។ ច្បាប់ជាតិមួយចំនួនផ្សេងទៀតចែងអំពីកិច្ចការពារសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម ក្នុងនោះ រួមទាំងច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធីផងដែរ។

## ៣. ស្ថានភាពនៃសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅកម្ពុជា

រួបកគំហើញជាច្រើនមានពិពណ៌នាក្នុងរបាយការណ៍របស់អ្នករាយការពិសេស លើកយកមកឆ្លុះបញ្ចាំងក្នុងបរិបទនៃប្រទេសកម្ពុជា ព្រោះលំហសេរីភាពនៅប្រទេសកម្ពុជាត្រូវបានកាត់បន្ថយ ហើយជារឿយៗសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមត្រូវបានរឹតត្បិត។ ករណីឧទាហរណ៍មានដូចខាងក្រោម៖

- *ការបំបិទលំហសេរីភាពរបស់ពលរដ្ឋ៖* អង្គការសម្ព័ន្ធពិភពលោកដើម្បីពង្រឹងសកម្មភាពពលរដ្ឋនិងសង្គមស៊ីវិល ("ស៊ីវីឃើស") បានចាត់ចំណាត់ថ្នាក់លំហសេរីភាពនៅកម្ពុជាថារង "ការគាបសង្កត់" បន្ទាប់ពីមានការបិទបណ្តាញសារព័ត៌មានឯករាជ្យជាលក្ខណៈទ្រង់ទ្រាយធំ ការរឹតត្បិតលើប្រតិបត្តិការរបស់អង្គការសង្គមស៊ីវិល និងការកំណត់មុខសញ្ញាជាប្រព័ន្ធនិងការយាយីលើអ្នកសារព័ត៌មាន អ្នកការពារសិទ្ធិមនុស្ស គណបក្សជំទាស់និងសំឡេងជំទាស់ផ្សេងៗទៀតក្នុងរយៈពេលប៉ុន្មានឆ្នាំមកនេះ។[13]
- *ការប្រើប្រាស់ច្បាប់ដើម្បីគាបសង្កត់លើការអនុវត្តសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម៖* ច្បាប់របស់ប្រទេសកម្ពុជាជាច្រើនបញ្ញត្តិការរឹតត្បិតលើការជួបប្រជុំនិងចងក្រងសមាគម។ ច្បាប់ស្តីពីសហជីព និងច្បាប់ទាក់ទងនឹងការបោះឆ្នោតបញ្ចូលបទប្បញ្ញត្តិដែលកំហិតលើការជួប



[11] ការអនុវត្តសិទ្ធិសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគម អាចមានការរឹតត្បិត ដែលកំណត់ដោយច្បាប់តែប៉ុណ្ណោះ និងដែល «*ចាំបាច់ក្នុងសង្គមប្រជាធិបតេយ្យ ក្នុងផលប្រយោជន៍នៃសន្តិសុខជាតិ ឬសុវត្ថិភាពសាធារណៈ សណ្តាប់ធ្នាប់សាធារណៈ ការការពារសុខភាពសាធារណៈឬសីលធម៌ ឬការការពារសិទ្ធិ និងសេរីភាពរបស់អ្នកដទៃ*» មាត្រា២១ និងមាត្រា២២ នៃ ក.អ.ស.ព.ន។

[12] ការបញ្ជាក់ពីក្រុមប្រឹក្សាធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា តាមរយៈសេចក្តីសម្រេចលេខ០៩២/០០៣/២០០៧ (ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០០៧)។

[13] អង្គការសម្ព័ន្ធពិភពលោកដើម្បីពង្រឹងសកម្មភាពពលរដ្ឋនិងសង្គមស៊ីវិល (ស៊ីវីឃើស) "ការគ្រប់គ្រងលំហសេរីភាពនៃពលរដ្ឋ" ប្រទេសកម្ពុជា៖https://monitor.civicus.org/country/cambodia/។

ប្រជុំ[14] និងមានច្បាប់មួយចំនួនទៀត ដូចជាច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល ច្បាប់ស្តីពីសហជីព និងច្បាប់ស្តីពីគណបក្សនយោបាយបញ្ញត្តិនូវលក្ខខណ្ឌរឹតត្បិតលើការចងក្រងសមាគម។[15] បន្ថែមលើច្បាប់ដែលបង្កការរឹតត្បិតទាំងនេះ ការអនុវត្តច្បាប់ទាំងនោះដោយបំពាននិងពុំត្រឹមត្រូវនាំឱ្យរារាំងដល់ការជួបប្រជុំ និងបន្ទច់បង្អាក់ដល់ការចងក្រងសមាគមនិងជាពិសេសបានរារាំងដល់ការអនុវត្តសេរីភាពជួបប្រជុំនិងចងក្រងសមាគម។ ឧទាហរណ៍នៅចន្លោះពីខែមេសា ឆ្នាំ២០១៩ ដល់ ខែមីនា ឆ្នាំ២០២០ ម.ស.ម.ក បានកត់ត្រាទុកចំនួនការជួបប្រជុំនិងប្រមូលផ្តុំមាន១៨៥ លើក (ក្នុងចំណោមនេះ ៥៤% ទាក់ទងនឹងដីធ្លី) មានការរឹតត្បិតចំនួន៥៤ លើក និងការរំលោភបំពានលើសិទ្ធិសេរីភាពក្នុងការជួបប្រជុំចំនួន២១លើក។ ម្យ៉ាងទៀត សមាជិករបស់សមាគម ជាពិសេស គណបក្សជំទាស់ និងសមាជិកសហជីពជារឿយៗរងការការយាយីតាមផ្លូវតុលាការនិងការចាប់ខ្លួន ដោយសារពួកគេចូលរួមក្នុងការជួបប្រជុំដោយសន្តិវិធី ជាពិសេសអ្នកការពារសិទ្ធិមនុស្ស។

- *ការប្រើកម្លាំងហួសប្រមាណដើម្បីតបតទៅនឹងការតវ៉ា:* មន្ត្រីអនុវត្តច្បាប់បានប្រើកម្លាំងហួសប្រមាណដើម្បីបំបែកការតវ៉ា។ ឧទាហរណ៍ នៅខែមករា ឆ្នាំ២០១៩ នគរបាលនិងកងរាជអាវុធហត្ថបានបើកការបាញ់ប្រហារលើអ្នកតវ៉ាក្នុងករណីវិវាទដីធ្លីមួយនៅឃុំបិតត្រាំង ក្នុងខេត្តព្រះសីហនុ។[16] នៅចន្លោះខែមេសា ឆ្នាំ២០១៩ ដល់ខែមីនា ឆ្នាំ២០២០ មានហេតុការណ៍ចំនួន៩ ដែលអាជ្ញាធរបានប្រើកម្លាំងបង្ក្រាបលើការជួបប្រជុំដោយសន្តិវិធី។[17]



- *ការកំណត់មុខសញ្ញាលើក្រុមជាក់លាក់:* ក្នុងឆ្នាំ២០១៧ គណបក្សជំទាស់ដ៏ធំមួយគឺគណបក្សសង្គ្រោះជាតិកម្ពុជាត្រូវបានតុលាការកំពូលសម្រេចរំលាយ។ ក្នុងឆ្នាំដដែលនោះ សមាជិកគណបក្សជំទាស់ចំនួន១១៨រូប ត្រូវបានហាមឃាត់ការធ្វើសកម្មភាពនយោបាយ ហើយលោក កឹម សុខា មេដឹកនាំគណបក្សជំទាស់ត្រូវបានចាប់ខ្លួនពីបទក្បត់ជាតិ។ អតីតសមាជិកនិងអ្នកគាំទ្រនៃគណបក្សសង្គ្រោះជាតិត្រូវបានគេកំណត់មុខសញ្ញាខ្លាំងឡើងៗ[18] ក្នុងនោះរួមទាំងការយាយីតាមផ្លូវតុលាការ និងការឃ្លាំមើលពីសំណាក់អាជ្ញាធរ ព្រមទាំងមានករណីជាច្រើននៃអំពើហិង្សាលើរាងកាយប្រព្រឹត្តដោយជនមិនស្គាល់អត្តសញ្ញាណផងដែរ។ ក្រុម

---

[14] ម.ស.ម.ក " ការការពារសេរីភាពមូលដ្ឋាន: ការពិនិត្យមើលទៅលើច្បាប់ជាតិ និងការអនុវត្តស្របតាមច្បាប់អន្តរជាតិ (ខែធ្នូ ឆ្នាំ២០១៩) ច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ទំព័រ២៨ និងទំព័រ៤០ https://cchrcambodia.org/index_old.php?url=project_page/project_page.php&p=report_detail.php&reid=140&id=3។

[15] ប្រភពខាងលើទំព័រ ២២ ទំព័រ ៣១ និងទំព័រ ៤០។

[16] ស៊ុន ណារិន " មនុស្សម្នាក់រងរបួសបន្ទាប់ពីកម្លាំងសន្តិសុខនៃប្រទេសកម្ពុជាបើកការបាញ់ប្រហារលើអ្នកតវ៉ា" សារព័ត៌មាន *សំឡេងសហរដ្ឋអាមេរិក* ថ្ងៃទី២៩ ខែមករា ឆ្នាំ២០១៩ https://www.voacambodia.com/a/one-seriously-injured-after-cambodian-security-forces-open-fire-on-protesters/4763701.html ។

[17] ម.ស.ម.ក របាយការណ៍ឃ្លាំមើលករណីរំលោភបំពានសេរីភាពមូលដ្ឋាន ខែមេសា ឆ្នាំ២០១៩ - ខែមីនា ឆ្នាំ២០២០។

[18] អង្គការសម្ព័ន្ធពិភពលោកដើម្បីពង្រឹងសកម្មភាពពលរដ្ឋនិងសង្គមស៊ីវិល (Civicus) សម្តែងក្តីបារម្ភចំពោះការយាយីតាមផ្លូវតុលាការលើអតីតសមាជិក គ.ស.ជ" ថ្ងៃទី០៣ ខែមិថុនា ឆ្នាំ២០១៩ www.civicus.org/index.php/media-resources/news/3882-csos-express-concern-over-judicial-harassment-of-former-cambodia-national-rescue-party-members។

ជាក់លាក់មួយចំនួនដទៃទៀតក៏ត្រូវបានកំណត់មុខសញ្ញាជាញឹកញាប់ផងដែរនៅកម្ពុជា ជាពិសេស សហជីព អ្នកការពារសិទ្ធិមនុស្ស អង្គការសង្គមស៊ីវិល និងប្រព័ន្ធផ្សព្វផ្សាយឯករាជ្យ។

- ***ការគំរាមចំពោះសេរីភាពជួបប្រជុំនិងចងក្រងសមាគមលើប្រព័ន្ធអ៊ីនធឺណិតៈ*** នៅរយៈពេលប៉ុន្មានឆ្នាំចុងក្រោយនេះ មានរបាយការណ៍ជាច្រើន លើកឡើងជុំវិញវិធានការរបស់រដ្ឋាភិបាលដែលធ្វើការរាំងខ្ទប់គេហទំព័រ ការលុបមាតិកា ការត្រួតពិនិត្យលើការចងក្រងបណ្តាញ ការឃាឃីលើអ្នកការពារសិទ្ធិមនុស្ស គណបក្សជំទាស់ អ្នកសារព័ត៌មាននិងប្រជាពលរដ្ឋដែលធ្វើសកម្មភាពរបស់ខ្លួននៅលើប្រព័ន្ធអ៊ីនធឺណិត។ ម្យ៉ាងវិញទៀត រដ្ឋាភិបាលបានប្រើប្រាស់ច្បាប់ដែលមានខ្លឹមសារទូលំទូលាយ និងមិនច្បាស់លាស់ដើម្បីរឹតត្បិតសេរីភាពក្នុងការជួបប្រជុំនិងចងក្រងសមាគមនៅលើប្រព័ន្ធអ៊ីនធឺណិត ហើយអ្នករាយការណ៍ពិសេសបានសម្តែងក្តីបារម្ភចំពោះអំណាចដែលហាមឃាត់សកម្មភាពលើប្រព័ន្ធអ៊ីនធឺណិតក្នុងឆ្នាំ២០១៨ តាមរយៈប្រកាសលេខ ១៧០ ស្តីពីការគ្រប់គ្រងការផ្សព្វផ្សាយតាមគេហទំព័រនិងបណ្តាញទំនាក់ទំនងសង្គម ដែលដំណើរការតាមប្រព័ន្ធអ៊ីនធឺណិត នៅព្រះរាជាណាក្រកម្ពុជា។



***សេរីភាពក្នុងការជួបប្រជុំដោយសន្តិវិធី និងចងក្រងសមាគមនៅកម្ពុជាក្នុងអំឡុងពេលជំងឺកូវីដ-១៩***

ចាប់តាំងពីការផ្ទុះឡើងនៃជំងឺកូវីដ-១៩ នៅដើមឆ្នាំ២០២០ លំហសេរីភាពកាន់តែប្រឈមថែមទៀតនៅប្រទេសកម្ពុជា និងមានការបន្តការបង្ក្រាបទៅលើការអនុវត្តសេរីភាពមូលដ្ឋាន ក្នុងនោះរួមទាំងសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម។ ចាប់តាំងពីខែមករា ឆ្នាំ២០២០៖

- យ៉ាងហោចសមាជិកគណបក្សសង្គ្រោះជាតិចំនួន១៥នាក់ ត្រូវបានចាប់ខ្លួន ជាមួយនេះរដ្ឋាភិបាលរងការចោទថាបានបង្ក្រាបលើសមាជិកគណបក្សជំទាស់។[19]
- មានការលើកឡើងជាច្រើនថា ថៅកែរោងចក្របានលើកយកបញ្ហាកូវីដ-១៩ ជាហេតុផលក្នុងការបញ្ឈប់កម្មករដើម្បីកាត់បន្ថយចំនួនមេ
- ក្រុមប្រជាពលរដ្ឋមួយក្រុមដែលប៉ុនប៉ងដាក់ញត្តិ ត្រូវបានបញ្ឈប់ ហើយការតវ៉ា និងការដើរហែក្បួនទទួលរងការរារាំង។[22]
- ការប្រារព្ធពិធីរំឭកវិញ្ញាណក្ខន្ធរបស់សកម្មជនដែលត្រូវបានឃាតកសម្លាប់ត្រូវបានរារាំង ក្នុងនោះរួមទាំងពិធីរំឭកខួបលោក ឈុត វុទ្ធី សកម្មជនបរិស្ថាន ហើយនិងការ

[19]អង្គការឃ្លាំមើលសិទ្ធិមនុស្ស "ប្រទេសកម្ពុជាៈ បញ្ឈប់ការបង្ក្រាបលើគណបក្សជំទាស់ (ថ្ងៃទី១៧ ខែកក្កដា ឆ្នាំ២០២០) www.hrw.org/news/2020/06/17/cambodia-end-crackdown-opposition។

[22] សូមមើលករណីឧទាហរណ៍ ឡុង គីមម៉ារីតា " កម្មកររោងចក្រដែលពុំទទួលបានប្រាក់ខែ ស្វែងរកអន្តរាគមន៍ពីនាយករដ្ឋមន្ត្រី" ( ថ្ងៃទី០១ ខែកក្កដា ឆ្នាំ២០២០ ) www.phnompenhpost.com/national/unpaid-factory-workers-seek-pms-intervention។

ដឹកនាំសហជីពនិងសមាជិក។[20] របាយការណ៍ទាំងនោះបង្ហាញថាមានសមាជិកសហជីពប្រមាណ ២.០០០ នាក់ត្រូវបានបញ្ឈប់ពីការងារ។

- សកម្មជន និងអ្នកការពារសិទ្ធិមនុស្សរងការយាយីនិងឃាត់ខ្លួនដើម្បីសាកសួរដោយសារចូលរួមឬឃ្លាំមើលការជួបប្រជុំដោយសន្តិវិធី។[21] ប្រារព្ធពិធីរំឭកខួបនៃឃាតកម្មលើលោកបណ្ឌិត កែម ឡី អ្នកវិភាគនយោបាយផងដែរ។[23]
- បណ្តាញបរិស្ថានក្នុងនោះ រួមមាន បណ្តាញសហគមន៍ព្រៃឡង់និងបណ្តាញមាតាធម្មជាតិត្រូវបានគេរាំងនិងបង្អាក់ការធ្វើសកម្មភាពជាច្រើនដង។[24]

## ៤. អនុសាសន៍

សេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមគឺជាសិទ្ធិមនុស្សមូលដ្ឋានរបស់មនុស្សគ្រប់រូប។ ដើម្បីពង្រឹងកិច្ចការពារសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅកម្ពុជា រាជរដ្ឋាភិបាលកម្ពុជាគួរពិនិត្យនិងអនុវត្តអនុសាសន៍ប្រកបដោយអត្ថន័យមួយចំនួនដែលអ្នករាយការណ៍ពិសេសស្តីពីសិទ្ធិជួបប្រជុំដោយសន្តិវិធីនិងចងក្រងសមាគមបានផ្តល់ជូន ជាពិសេស អនុសាសន៍មានលើកឡើងក្នុងរបាយការណ៍ឆ្នាំ២០១៨ និងឆ្នាំ២០១៩ ដែលមានដូចខាងក្រោមៈ[25]

១. ធ្វើវិសោធនកម្មច្បាប់ដែលរឹតត្បិតសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅកម្ពុជា ក្នុងនោះរួមទាំងបទប្បញ្ញត្តិមួយចំនួននៃច្បាប់ស្តីពីការធ្វើបាតុកម្មដោយសន្តិវិធី ច្បាប់ស្តីពីគណបក្សនយោបាយ ច្បាប់ស្តីពីសមាគមនិងអង្គការមិនមែនរដ្ឋាភិបាល និងច្បាប់ស្តីពីសហជីព។

---

[20] មជ្ឈមណ្ឌលធុរកិច្ចនិងសិទ្ធិមនុស្ស "កម្មករកាត់ដេរនៅប្រទេសមីយ៉ាន់ម៉ា និងកម្ពុជាចោទប្រកាន់រោងចក្រលើកយកបញ្ហាកូវីដ-១៩ជាលេសដើម្បីបញ្ឈប់កម្មករដែលចូលរួមក្នុងសកម្មភាពសហជីព" (ថ្ងៃទី០៨ ខែឧសភា ឆ្នាំ២០២០) https://www.business-humanrights.org/en/garment-workers-in-myanmar-cambodia-allege-factories-are-using-covid-19-as-pretext-to-dismiss-unionised-workforce។

[21] សូមមើលករណីឧទាហរណ៍ ឃី សុវុទ្ធី: " មនុស្ស៦នាក់ត្រូវបានឃាត់ខ្លួនដោយសារតវ៉ារឿងបង់បំណុលអោយគ្រឹះស្ថានមីក្រូហិរញ្ញវត្ថុ (សារព័ត៌មាន *ខេមបូចា* ថ្ងៃទី១៤ ខែឧសភា ឆ្នាំ២០២០) https://cambojanews.com/six-detained-for-protesting-microfinance-repayments/។

[23] សូមមើលករណីឧទាហរណ៍ យួន ណារីម "អាជ្ញាធរបញ្ឈប់អ្នកដំណើរតាមរថយន្តឆ្ពោះទៅចូលរួមពិធីបុណ្យរំឭកខួបនៃមរណៈភាពលោកបណ្ឌិត កែម ឡី" សារព័ត៌មាន*ខេមបូចា* ថ្ងៃទី១០ ខែកក្កដា ឆ្នាំ២០២០) https://cambojanews.com/authorities-stop-convoy-headed-to-ceremony-for-kem-leys-death ។

[24] សូមមើលករណីឧទាហរណ៍ ប៊ិច សុធារី " ក្រសួងហាមប្រាមក្រុមប្រជាពលរដ្ឋនានាក្នុងការរៀបចំពិធីសូត្រមន្ត" (ខ្មែរថាមស៍ ថ្ងៃទី២៤ ខែកុម្ភៈ ឆ្នាំ២០២០) www.khmertimeskh.com/50694289/ministry-prohibits-groups-events-in-prey-lang-protected-forests។

[25] ប្រភពខាងលើ ៩ (ឯកសារ អ.ស.ប. ក/៤១/៤១),(ឯកសារ អ.ស.ប. ក/៧៣/២៧៩ និងប្រភពខាងលើ ៦ (ឯកសារ អ.ស.ប. ក/៤៧/៣៤៧)។

២. រៀបចំការបណ្តុះបណ្តាលជាមួយអាជ្ញាធរអំពីការអនុវត្តច្បាប់ទាំងនេះដោយត្រឹមត្រូវទាក់ទងនឹងសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម។

៣. បញ្ឈប់ការចាប់ខ្លួន និងការប្រើកម្លាំងដោយបំពានប្រឆាំងនឹងបុគ្គលដែលអនុវត្តសិទ្ធិក្នុងការជួបប្រជុំ និងចងក្រងសមាគមរបស់ពួកគេ រួមទាំងសិទ្ធិសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគមនៅលើប្រព័ន្ធអ៊ីនធឺណិត។

៤. ទទួលស្គាល់ពីសារៈសំខាន់នៃសេរីភាពក្នុងការជួបប្រជុំ និងចងក្រងសមាគម និងលំហសេរីភាពនៃពលរដ្ឋដែលមានលក្ខណៈងាយស្រួលក្នុងការសម្រេចបានការអភិវឌ្ឍប្រកបដោយចីរភាព និងកិច្ចសហការជាមួយសង្គមស៊ីវិលក្នុងភាពជាដៃគូក្នុងការអភិវឌ្ឍប្រកបដោយចីរភាព។

**សម្រាប់ព័ត៌មានបន្ថែម សូមទាក់ទងលោក សួន យុធ្យា នាយកតស៊ូមតិ ម.ស.ម.ក តាមរយៈទូរស័ព្ទ +៨៥៥ (០) ៨៨ ៨១ ៤២ ៧៨៣ ឬសារអេឡិចត្រូនិច yuthyia@cchrcambodia.org។**